**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

-សំណុំរឿងព្រហ្មទណ្ឌ លេខ: ៨០៧ អក
ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២
-សាលក្រមលេខ៖ **១៣៥** (ឃ)
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ដោយមាន សមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៧ អក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ដែលមាន ជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ: [redacted] **សុភារម្យ** ភេទប្រុស អាយុ ១៧ឆ្នាំ (កើតថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរសិស្ស (ថ្នាក់ទី១២) ទីកន្លែងកំណើតនៅភូមិ[redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ: [redacted] សុភាព (រ) ម្តាយឈ្មោះ: [redacted] សារ៉ាត់ (រ) នៅលើវ ទោសពីមុន គ្មាន។ (ឃុំខ្លួនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

២-ឈ្មោះ: [redacted] **សិទ្ធិគុណ** ភេទប្រុស អាយុ ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ ណាក់ (ស) ម្តាយឈ្មោះ:[redacted] ដារ៉ា (រ) នៅលើវ ទោសពីមុន គ្មាន។ (ឃុំខ្លួនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

៣-ឈ្មោះ: [redacted] **សីហាគុន** ភេទប្រុស អាយុ ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មុខរបរ សិស្ស (ថ្នាក់ទី១០) ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ន នៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ: [redacted] តាំ (រ) ម្តាយឈ្មោះ: [redacted] ស៊ីថា (ស) នៅលើវ ទោសពីមុន គ្មាន។ (ឃុំខ្លួនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

៤-ឈ្មោះ: [redacted] **ម៉េងគួ** ភេទប្រុស អាយុ ១៨ឆ្នាំ (កើតឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្នផ្ទះលេខ



Scanned with CamScanner

[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុវណ្ណ (រ) ម្ដាយឈ្មោះ [redacted] មួយ (រ) នៅលីវ។ (គេចខ្លួន)

៥-ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត ភេទប្រុស អាយុ ១៦ឆ្នាំ (កើតឆ្នាំ២០០៦) ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ថេង (រ) ម្ដាយឈ្មោះ [redacted] ស៊ីម (រ) នៅលីវ ។ (ឃុំខ្លួននៅភ្នំពេញ)

៦-ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុ ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៦) ជនជាតិខ្មែរ មុខរបរ លើកឥវ៉ាន់ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅផ្ទះជួល សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ថន (រ) ម្ដាយឈ្មោះ [redacted] ឡេង (រ) នៅលីវ ។ (គេចខ្លួន)

៧-ឈ្មោះ [redacted] មីណា ភេទប្រុស អាយុ ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម៉ិច (រ) ម្ដាយឈ្មោះ [redacted] សុភិន (រ) នៅលីវ ទោសពីមុន គ្មាន។ (គេចខ្លួន)

៨-ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីលំនៅបច្ចុប្បន្ននៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ (ឃុំខ្លួននៅភ្នំពេញ)

៩-ឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] រាជធានីភ្នំពេញ។ (គេចខ្លួន)

១០-ឈ្មោះ [redacted] លីហួរ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] រាជធានីភ្នំពេញ។ (គេចខ្លួន)

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ) ប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ម៉េងគួ។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សីហគុន, ឈ្មោះ [redacted] សុភារម្យ និងឈ្មោះ [redacted] សិទ្ធិគុណ។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ, ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហួរ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមលាង ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ នៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង១០នាទី ទៀបភ្លឺ ស្ថិតនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានករណី លួចមានស្ថានទម្ងន់ទោស(កាប់យកម៉ូតូ) ដែលបង្កឡើងដោយជនសង្ស័យចំនួន ១០នាក់ រួមមាន ១.ឈ្មោះ [redacted] សីហគុន ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សិទ្ធិគុណ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សុភារម្យ ភេទប្រុស អាយុ ១៧ឆ្នាំ, ៤.ឈ្មោះ [redacted] ម៉េងគួ



Scanned with CamScanner

ភេទប្រុស អាយុ ១៨ឆ្នាំ, ៥.ឈ្មោះ [redacted]វ៉ាន់ថា ហៅ ស្វិត ភេទប្រុស អាយុ ១៨ឆ្នាំ, ៦.ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុ ១៧ឆ្នាំ, ៧.ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ ភេទប្រុស អាយុ ២០ឆ្នាំ, ៨.ឈ្មោះ [redacted]មីណា ភេទប្រុស អាយុ ១៨ឆ្នាំ, ៩.ឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ និង១០.ឈ្មោះ [redacted] លីហួរ ភេទប្រុស អាយុ ១៨ឆ្នាំ ពេលកើតហេតុជនរងគ្រោះឈ្មោះ [redacted] គឹមលាង ភេទប្រុស អាយុ ១៩ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ពណ៌ស ស៊េរីឆ្នាំ២០២១ ពាក់ផ្លាកលេខ កណ្ដាល 1AM-6603 ចេញទៅកន្លែងធ្វើការនៅភូមិចិនកោះ ឃុំគគីរ ពេលជិះដល់មុខវត្តកោះសត្ថារាម ស្ថិតក្នុងចំណុចកើតហេតុខាងលើ ស្រាប់តែមានជនសង្ស័យចំនួន ១០នាក់ បានជិះម៉ូតូមកកៀររួចបានយកកាំបិតប៉័ងតោ កាប់ជនរងគ្រោះ ចំក្បាលចំនួន ០៣ កន្លែង (ដេរអស់ចំនួន ៣០ថ្នេរ) និងខ្នងចំនួន ០២កាំបិត រួចបានយកម៉ូតូជិះនៅភ្នំពេញគេចខ្លួនតែម្ដង។ បន្ទាប់មក ជនរងគ្រោះឈ្មោះ [redacted] គឹមលាង បានទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគគីរ។ ភ្លាមនោះ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលគគីរ សហការណ៍ជាមួយកម្លាំងផ្នែកនគរបាលយុត្តិធម៌ស្រុកកៀនស្វាយ និងសហការជាមួយកម្លាំងនគរបាលខណ្ឌច្បារអំពៅធ្វើការឃាត់ខ្លួនជនសង្ស័យបានចំនួន ០៣នាក់ រួមមាន ១.ឈ្មោះ [redacted] សីហតុន, ២.ឈ្មោះ [redacted] សិទ្ធិគុណ និងឈ្មោះ [redacted] សុភារម្យ ដើម្បីយកមកធ្វើការសាកសួរ ហើយនៅចំពោះមុខសមត្ថកិច្ចជនសង្ស័យទាំង០៣នាក់ បានឆ្លើយសារភាពថា "ពួកខ្លួន និងបក្ខពួកចំនួន ០៧នាក់ទៀត ពិតជាបានកាប់យកម៉ូតូរបស់ជនរងគ្រោះពិតមែន"។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ **៩៨០ ដកសព** ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ដែលប្ដឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ [redacted] **សុភារម្យ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **សិទ្ធិគុណ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **សីហតុន** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **ម៉េងគួ** ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] **វ៉ាន់ថា ហៅ ស្វិត** ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] **ជាតិ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **មីណា** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **ម៉េងហាក់ ហៅ កណ្ដុរ** ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ **ស៊ី** ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] **លីហួរ** ភេទប្រុស អាយុ ១៨ឆ្នាំ ទៅជំនុំជម្រះ ។

**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ **៩៧៥ ដកដស** ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្ដាល ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សុភារម្យ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **សិទ្ធិគុណ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **សីហតុន** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **ម៉េងគួ** ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] **វ៉ាន់ថា ហៅ ស្វិត** ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] **ជាតិ** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **មីណា** ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] **ម៉េងហាក់ ហៅ កណ្ដុរ** ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ **ស៊ី** ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] **លីហួរ** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទៅជំនុំជម្រះ ពីបទៈ **លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ)** ប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សីហតុន** បានឆ្លើយនាពេលសវនាការថា កន្លងមកខ្លួនធ្លាប់ចូលរួម ធ្វើសកម្មភាពប្លន់ម៉ូតូគេពីរលើកមកហើយ តែពុំបានសម្រេច យកម៉ូតូគេបានទេ គឺលើកទីមួយ និងលើកទីពីរ នៅស្រុកស្អាង មិនចាំថ្ងៃខែទេ ក្នុងឆ្នាំ២០២២ និងលើកទីបី ធ្វើដំណើរនៅតាមផ្លូវកៀនស្វាយ ម៉ូតូអស់សាំង ចូល



Scanned with CamScanner

ចាក់សាំងម៉ូតូពីរគ្រឿង និងម៉ូតូបីគ្រឿងទៅហូរ លុះចាក់សាំងរួច ជិះទៅតាមក្រោយ តែពុំទាន់ម៉ូតូបីគ្រឿងនោះទេ ហើយខ្លួនក៏ពុំដឹង ម៉ូតូបីគ្រឿងនោះទៅណាដែរ ។ បន្ទាប់មកឈ្មោះ គូ បានទូរស័ព្ទមកឈ្មោះ ភារម្យ ឱ្យទៅចាំនៅស្ពានច្បារអំពៅ ពេលនោះម៉ូតូពួកខ្លួនពីរគ្រឿងជិះត្រឡប់មកវិញ ដល់ម្តុំបឹងស្នោក៏ត្រូវសមត្ថកិច្ចឃាត់បានមនុស្សបីនាក់ មានខ្លួន, ឈ្មោះ គុណ និងឈ្មោះ ភារម្យ តែឈ្មោះ ហួរ បានរត់គេចខ្លួនបាត់។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតទូរស័ព្ទបានបីគ្រឿង ម្នាក់មួយគ្រឿង និងម៉ូតូពីរគ្រឿង ក្នុងនោះមានម៉ូតូមួយគ្រឿងម៉ាក HONDA សេរីឆ្នាំ២០១៩។ ចំពោះសកម្មភាពយកម៉ូតូគេនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ខ្ញុំបាទមិនបានចូលរួមទេ ដោយសារតែពេលនោះម៉ូតូរបស់ខ្ញុំអស់សាំង ហើយបានចូលចាក់សាំង ក្រុមខ្ញុំផ្សេងទៀតទៅមុនបាត់ទៅ។ បន្ទាប់មក មានក្រុមខ្ញុំ បានទូរស័ព្ទមកប្រាប់ថា យកម៉ូតូគេបានមួយគ្រឿងហើយ ឱ្យពួកខ្ញុំចាំនៅស្ពានច្បារអំពៅ។

-ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិគុណ បានឆ្លើយនាពេលសវនាការថា កន្លងមកខ្លួនមិនដែលធ្វើសកម្មភាពប្លន់ម៉ូតូរបស់គេទេ ហើយនៅថ្ងៃកើតហេតុទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោងប្រហែល ០៣ និង ៣០នាទី ទៀបភ្លឺ ត្រូវសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ គុន, ឈ្មោះ ភារម្យ និងឈ្មោះ លីហួរ រត់គេចខ្លួន ពេលពួកខ្លួនបួននាក់ជិះម៉ូតូពីរគ្រឿង ត្រឡប់មកផ្ទះ ឃាត់ខ្លួននៅម្តុំជិតស្ពានច្បារអំពៅ បានដកហូតម៉ូតូពីរគ្រឿង ទូរស័ព្ទខ្លួនមួយគ្រឿង និងគ្នាខ្លួនពីរនាក់ទៀត ព្រមទាំងទូរស័ព្ទម្នាក់មួយគ្រឿងដែរ។ នៅម៉ោង ០៤រសៀល ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ខ្លួនដើរទៅផឹកកាហ្វេ លុះដល់ម៉ោង ០៦ល្ងាច ឈ្មោះ គុន ហៅ ខ្លួនជិះម៉ូតូជាមួយវា ទៅកន្លែងបុកប៊ីយ៉ែ ចេញពីបុកប៊ីយ៉ែ ទៅផ្ទះរបស់ឈ្មោះ នុន អង្គុយលេង ក៏មានឈ្មោះ គូ ទូរស័ព្ទហៅខ្លួន ខ្លួនក៏ជិះម៉ូតូជាមួយឈ្មោះ គុន និងឈ្មោះ ជាតិ ជិះម៉ូតូមួយផ្សេង ទៅច្បារអំពៅ ទៅផ្ទះរបស់ឈ្មោះ នី ក៏ជុំគ្នា ណាត់នៅភ្នំពេញម្តុំវត្តបុទុម រកគូសត្រូវមិនឃើញ ក៏មកប៉ុស្តិ៍បាយ៉ន ក៏មានឈ្មោះ គូ, ឈ្មោះ កណ្តុរ ថាទៅលេងកៀនស្វាយ ខ្លួន មិន ដឹងថាទៅធ្វើអ្វីទេ បើដឹងថាទៅប្លន់ម៉ូតូគេខ្លួនមិនទៅទេ។ ហើយចេញពីបាយ៉នទៅកៀនស្វាយ បានពាក់កណ្តាលផ្លូវម៉ូតូពីរគ្រឿងចូលចាក់សាំងម៉ូតូមួយគ្រឿង ខ្លួនជិះជាមួយឈ្មោះ គុន និងម៉ូតូមួយគ្រឿងទៀត ឈ្មោះ ភារម្យ ឌុបឈ្មោះ ហួរ ហើយម៉ូតូបីគ្រឿងទៀតជិះទៅបាត់ មិនដឹងគេទៅណាធ្វើអ្វីទេ លុះចាក់សាំងរួច ម៉ូតូពួកខ្លួនពីរគ្រឿងជិះតាមក្រោយរត់មិនទាន់ និងរកគេមិនឃើញ ក៏ត្រឡប់មកចាំនៅកៀនស្វាយ នៅកន្លែងលក់ដូរ ក៏មានឈ្មោះ គូ ទូរស័ព្ទមកឈ្មោះ ភារម្យ ថាបានម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ហើយឈ្មោះ គូ បានប្រាប់ឱ្យពួកខ្លួនជិះម៉ូតូពីរគ្រឿងមកស្ពានច្បារអំពៅ ពេលត្រឡប់មកជិតស្ពានច្បារអំពៅ ត្រូវសមត្ថកិច្ចឃាត់ខ្លួន បានមនុស្ស បីនាក់ និងម៉ូតូបីគ្រឿង ដោយឈ្មោះ ហួរ បានរត់គេចខ្លួន។ ខ្ញុំមិនមានមុខរបរអ្វីទេ ខ្ញុំជួយលក់ម៉ែខ្ញុំ។ ខ្ញុំមិនធ្លាប់ធ្វើសកម្មភាពអ្វីទេ។ ខ្ញុំទើបតែទៅកៀនស្វាយនោះជាលើកទី១។ ពេលពួកខ្លួនជិះម៉ូតូដល់តំបន់ច្បារអំពៅ គឺមានឈ្មោះ គូ តេមកឈ្មោះ ភារម្យ ដោយបានប្រាប់ថា បានម៉ូតូ០១គ្រឿង ហើយឱ្យពួកខ្លួនចាំនៅច្បារអំពៅ បន្ទាប់មកពួកខ្លួនក៏ជិះម៉ូតូមកចាំពួកគាត់នៅផ្ទះច្បារអំពៅ ។ ខ្ញុំមិនបានព្រមព្រៀងក្នុងការយកម៉ូតូគេនោះទេ។ ខ្ញុំបាទមិនបានដឹងអ្វីទេ។ ខ្ញុំបាទមិនទទួលស្គាល់ការចោទប្រកាន់នោះទេ។ ខ្ញុំទើបតែដឹងថាពួកគាត់ទៅឆក់យកម៉ូតូគេ នៅពេលដែលពួកគាត់តេមកតែប៉ុណ្ណោះ។ ពេលដែលខ្ញុំលឺទូរស័ព្ទថា គេកាច់កម៉ូតូបានហើយ តែនៅតែទៅតាមគេទៀត ដោយសារខ្ញុំមិនមានម៉ូតូជិះមកផ្ទះវិញ ពេលនោះខ្ញុំជិះម៉ូតូជាមួយឈ្មោះ [redacted] សីហគុន ដោយឈ្មោះ [redacted] សីហគុន ជាអ្នកឌុបខ្ញុំ។

-ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ បានឆ្លើយនាពេលសវនាការថា ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពប្លន់យកម៉ូតូគេសរុបចំនួនបីលើកមកហើយ តែលើកទីមួយ និងទីពីរ មិនបានទេ ដោយលើកទីបី នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ពីរ យប់ មានគ្នាចំនួនដប់នាក់ មានឈ្មោះ [redacted] លីហួរ, ឈ្មោះ កណ្តុរ



Scanned with CamScanner

ឈ្មោះ អាតុង, ឈ្មោះ គុណ, ឈ្មោះ អាគូ, ឈ្មោះ ស្និត, ឈ្មោះ ជាតិ, ឈ្មោះ ស៊ី, ឈ្មោះ មីណា និងខ្លួន។ ពេលធ្វើសកម្មភាពប្លន់ម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ពណ៌ស នោះ ឈ្មោះ ស្និត, ឈ្មោះ កណ្តុរ, ឈ្មោះ គូ, ឈ្មោះ ជាតិ, ឈ្មោះ ស៊ី និងឈ្មោះ អាមីណា ដោយខ្លួនពុំបាននៅតាមគ្នាប្រាំមួយនាក់នេះទេ ព្រោះម៉ូតូខ្លួនចូលចាក់សាំងពីរគ្រឿង។ ចំពោះម៉ូតូខ្លួនពីរគ្រឿងចាក់សាំងមានឈ្មោះ [redacted] ហួរ ជិះម៉ូតូពីក្រោយខ្លួន ម៉ាក សង់ សេ១២៥ ពណ៌ខ្មៅ ជារបស់ម្តាយខ្លួន និងម៉ូតូមួយគ្រឿងទៀតជារបស់ឈ្មោះ គុន និងឈ្មោះ គុណ ជិះពីក្រោយនៅស្រុកកៀនស្វាយ រកគ្នាខ្លួនប្រាំមួយនាក់មិនឃើញ ក៏ឈប់ម៉ូតូនៅកន្លែងគេលក់ដូរ ហើយមានគ្នាខ្លួនឈ្មោះ គូ ទូរស័ព្ទមកច្បារអំពៅ ក៏ខ្លួនជិះមកម៉ុំបឹងស្នោ ក៏សមត្ថកិច្ចមកឃាត់ពួកខ្លួន មានឈ្មោះ គុណ , ឈ្មោះ គុន និងខ្លួន ចំពោះម៉ូតូសមត្ថកិច្ចឃាត់ទុកទាំងពីរគ្រឿងនៅស្នងការ។ ពេលប៉ូលីសចាប់ខ្លួននោះ គឺនៅច្បារអំពៅ នៅលើផ្លូវ។ ចំពោះកាំបិត គឺឈ្មោះ គូ និងឈ្មោះ កណ្តុរ ជាអ្នកយកមក គោលបំណងវាជិះយកទៅភ្នំពេញ ដោយលឺវាថាឈ្លោះគ្នា ហើយជិះរកមើលមិនឃើញ បន្ទាប់មក ពួកវាក៏បបួលជិះទៅកៀនស្វាយលេង ។ ពាក្យថា "ចេញរក" នោះ ខ្ញុំមិនបានឆ្លើយទេ។ ខ្លួនទៅចូលរួមជិះជាមួយគេ ហើយម៉ូតូអស់សាំង ខ្ញុំក៏ចូលចាក់សាំង គេក៏ជិះទៅចោលអស់ទៅ។ ខ្លួនទើបប្រព្រឹត្តម្តងនេះទេ។ ពេលឆ្លើយនៅប៉ូលីស គឺប៉ូលីសគាត់បានវាយខ្លួន។ ចំពោះនៅដំណាក់កាលអយ្យការ គឺមិនបានវាយធ្វើបាប ឬបង្ខំអ្វីទេ។ ខ្ញុំធ្លាប់ចូលរួមសកម្មភាពចំនួន០៣ដង មកហើយ ប៉ុន្តែមិនបានសម្រេចនោះទេ។ ពេលនោះឈ្មោះ គូ តេមកឈ្មោះ សីហាតុន ហើយខ្លួនជាអ្នកលើក ហើយវាប្រាប់ថា មកផ្ទះនៅច្បារអំពៅ មក។ ខ្ញុំបាទមិនបានទទួលចំណែកលុយពីការលក់ម៉ូតូទេ ។ ខ្លួនទទួលស្គាល់ការចោទប្រកាន់របស់តំណាងអយ្យការ។ កាំបិត និងដាវ នោះ គឺឈ្មោះ កណ្តុរ ជាអ្នកយកទៅលាក់ទុកនៅព្រៃក្រោយផ្ទះខ្ញុំ ដោយគាត់យកមកទុកពីរទៅបីថ្ងៃហើយ។ ខ្ញុំបាទមិនបានកាន់កាប់អាវុធនោះទេ ដោយឈ្មោះ កណ្តុរជាអ្នកយកទៅទុកនៅក្រោយផ្ទះខ្ញុំទេ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted]វ៉ាន់ថា ហៅ ស្និត បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ប្រហែលម៉ោង ២១យប់ ពួកខ្លួនបានជុំគ្នានៅផ្ទះរបស់ឈ្មោះ ណើ ភេទប្រុស មានគ្នា ១០នាក់ ពេលនោះឈ្មោះ គូ និងឈ្មោះ ភារម្យ បានទៅយកដាវនៅផ្ទះរបស់ឈ្មោះ ភារម្យ ប្រហែលប្រាំបីដើម គោលបំណងទៅកាប់ពួកក្រុមលៀសហាល នៅមុខវត្តបុទុម ពេលទៅដល់វិមានឯករាជ្យ ក៏ឃើញមានសមត្ថកិច្ច ក៏ត្រឡប់មកជុំគ្នានៅស្ថានីយទូរទស្សន៍បាយ័ន លុះដល់ម៉ោង ១២យប់ ពួកខ្លួនជិះម៉ូតូទៅកៀនស្វាយ ក្នុងគោលបំណងដើម្បីប្លន់ ពេលធ្វើដំណើរទៅជិះម៉ូតូប្រាំគ្រឿង ហើយមិត្តភក្តិខ្លួន ពីរម៉ូតូមិនដឹងបាត់ទៅណា។ រហូតដល់ម៉ោងប្រហែល ០១ និង ៣០នាទី ឈានចូលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ ជាតិ, ឈ្មោះ គូ, ឈ្មោះ ស៊ី, ឈ្មោះ មីណា, ឈ្មោះ កណ្តុរ និងខ្លួន បានធ្វើសកម្មភាពកាប់ប្លន់ម៉ូតូពីមនុស្សប្រុសម្នាក់ជិះម៉ូតូ HONDA SCOOPY សេរីឆ្នាំ២០២១ ពេលនោះឈ្មោះ កណ្តុរ បានកាប់បុរសនោះចំនួនមួយកាំបិត ហើយដួល បន្ទាប់មកឈ្មោះ ជាតិ ក៏បានចុះទៅកាប់ជាច្រើនកាំបិតទៀតមិនដឹងត្រូវកន្លែងណាទេ បន្ទាប់មកឈ្មោះ ជាតិ ក៏បានលើកម៉ូតូជិះចេញ ឈ្មោះ គូ បានប្រាប់ពួកខ្លួនឱ្យទៅចាំនៅផ្សារឃ្លាំងរំសេវ ទៅដល់ហាងលក់បាន ចំនួន ៩០០ (ប្រាំបួនរយដុល្លារអាមេរិក) ប៉ុន្តែខ្លួនមិនដឹងថាវាលក់នៅហាងណាទេ បន្ទាប់មកពួកខ្លួនបានទៅលេងខេត្តកំពត លុះដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ បានឆ្លើយនាពេលសវនាការថា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ពួកខ្លួនមានគ្នា ប្រាំនាក់ មានឈ្មោះ គូ ភេទប្រុស, ឈ្មោះ ស្និត ភេទប្រុស, ឈ្មោះ ជាតិ ភេទប្រុស, ឈ្មោះ ស៊ី ភេទប្រុស បានទៅជុំគ្នានៅផ្ទះរបស់ឈ្មោះ ណើ ដោយមានគ្នា ១០នាក់

និងម៉ូតូប្រាំគ្រឿង ពេលជុំគ្នាឈ្មោះ គូ និងឈ្មោះ ភារម្យ បានទៅយកដាវ និងកាំបិតចំនួន ប្រាំបីដើម ដោយឈ្មោះ គូ បបួលពួកខ្លួន ទៅកាប់អ្នកលក់សៀសហាល ពេលទៅឃើញសមត្ថកិច្ច ពួកខ្លួនក៏នាំគ្នាទៅស្ថានីយប៉ុស្តិ៍បាយ័ន ដល់ម៉ោងប្រហែល មួយរំលងអាធ្រាតឈានចូលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ គូ បបួលពួកខ្លួនទៅកាប់គេនៅស្រុកកៀនស្វាយ ដោយពេលនោះខ្លួនជិះជាមួយឈ្មោះ គូ, ឈ្មោះ ស៊ិត ជិះម៉ូតូជាមួយឈ្មោះ ជាតិ, ឈ្មោះ មីណា ជិះជាមួយឈ្មោះ ស៊ី, ឈ្មោះ ហួរ ជិះជាមួយឈ្មោះ ភារម្យ និងឈ្មោះ គុន ជិះជាមួយឈ្មោះ គុណា។ ពេលដល់ស្រុកកៀនស្វាយ ស្រាប់តែម៉ូតូរបស់ឈ្មោះ ហួរ និងឈ្មោះ គុន បានអស់សាំង រួចពួកខ្លួនជិះម៉ូតូបីគ្រឿង ទៅដល់ចំណុចផ្សារគគីរក៏ឃើញមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាក HONDA SCOOPY ពណ៌ស ស៊េរីឆ្នាំ២០២១ ពួកខ្លួនក៏ជិះតាមដល់វត្តកោះ ខ្លួនក៏បានកាប់បុរសម្នាក់នោះ មួយកាំបិតប៉ុងតោ បន្ទាប់មកឈ្មោះ ជាតិ និងឈ្មោះ ស៊ិត បានជិះដេញបុរសម្នាក់នោះដល់មុខវត្ត បុរសម្នាក់នោះក៏ដួលម៉ូតូ ហើយឈ្មោះ ជាតិ បានកាប់ថែមជាច្រើនកាំបិត ហើយឈ្មោះ ជាតិ បានលើកម៉ូតូបុរសម្នាក់នោះជិះទៅបាត់ រួចឈ្មោ គូ បានប្រាប់ឱ្យខ្លួនទៅចាំនៅកន្លែងលក់ម៉ូតូនៅឃ្លាំងរំសេវ ដោយឈ្មោះ ជាតិ និងឈ្មោះ គូ លក់ម៉ូតូបានចំនួន ៩០០ (ប្រាំបួនរយដុល្លាអាមេរិក) រួចពួកខ្លួនបានទៅលេងខេត្តកំពត លុះដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួន និងបក្ខពួកធ្លាប់ធ្វើសកម្មភាពកាប់ប្លន់នៅស្រុកស្អាង ប៉ុន្តែមិនបានសម្រេច ទើបតែធ្វើសកម្មភាពនៅស្រុកកៀនស្វាយបានសម្រេច។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមលាង** បានឆ្លើយថា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ០១ និង ៣០នាទី កណ្តាលអាធ្រាតខ្លួនបានជិះម៉ូតូម៉ាក ស្កុបពី ពណ៌ស ស៊េរីឆ្នាំ២០២១ ពាក់ផ្លាកលេខ កណ្តាល 1AM-6603 ចេញពីផ្ទះរបស់ឈ្មោះ [redacted] ឆាយ ភេទប្រុស នៅភូមិកោះទៀវ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដើម្បីទៅទិញគុយទាវនៅចំណុចមុខមន្ទីរពេទ្យបង្អែកស្រុកកៀនស្វាយ ខ្លួនក៏ឈប់ម៉ូតូទិញគុយទាវទិញរួចហើយ ខ្លួនក៏ជិះម៉ូតូទៅផ្ទះរបស់ឈ្មោះ [redacted] ឆាយ វិញ។ ជិះម៉ូតូដល់មុខខ្លោងទ្វារវត្តកោះ ស្រាប់តែមានជនមិនស្គាល់ ជិះម៉ូតូ បីគ្រឿង ម៉ាកហុងដា ១២៥ ចំនួន ពីរគ្រឿង និងម៉ូតូ មួយគ្រឿង ម៉ាកស្កុបពី ពណ៌ខ្មៅ មិនចាំស៊េរី ដោយមានគ្នា ០៧នាក់ បានជិះម៉ូតូមកជិតខ្លួន រួចបានធាក់ម៉ូតូខ្លួនបណ្តាលឱ្យដួល ហើយជនមិនស្គាល់បានយកកាំបិតប៉ុងតោមកកាប់ចំមូក មួយកាំបិត បន្ទាប់មកខ្លួនបានប្រតាយប្រតប់ជាមួយជនមិនស្គាល់មិនឱ្យយកម៉ូតូទៅ រួចក៏មានគ្នាវាមកកាប់ខ្លួនចំនួនពីរប៉ុងតោទៀត ចំពីក្រោយក្បាល បណ្តាលឱ្យមានរបួសចេញឈាម ពេលនោះជនមិនស្គាល់បានលើកម៉ូតូរបស់ខ្លួនជិះទៅខាងភ្នំពេញបាត់ទៅ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] **រ៉ាវី ហៅ តី** បានឆ្លើយនាពេលសវនាការថា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០៣ និង ២០នាទី ខ្លួនកំពុងសំរាកនៅផ្ទះ ថៅកែប្តី បានមកប្រាប់ថា ប្តីខ្លួនត្រូវចោរកាប់ចំនួន ពីរកាំបិត ចំក្បាល និងខ្នងយកម៉ូតូ តែយកមិនបាន ពេលខ្លួនមកមើលប្តីនៅមន្ទីរពេទ្យបង្អែកស្រុកកៀនស្វាយ ប្តីខ្លួនបានប្រាប់ថា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ០២ និង ១០នាទី គាត់កំពុងជិះម៉ូតូតាមផ្លូវ ស្រាប់តែជនសង្ស័យចំនួន បីម៉ូតូ មិនដឹងប៉ុន្មាននាក់ទេ កាប់ចំក្បាលខ្នង តែយកម៉ូតូមិនបានទេ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] **សាវ៉េត** បានឆ្លើយនាពេលសវនាការថា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ២១ និង ៣០នាទី ខ្លួនកំពុងអង្គុយលេងមុខផ្ទះជាមួយប្អូនប្រុសឈ្មោះ [redacted] លីនណា ភេទប្រុស ស្រាប់តែម៉ូតូចំនួន ០៧ម៉ូតូ ម៉ាកហុងដាសេ ១២៥ មានគ្នា ១០នាក់ ក្នុងចំណោម ១០នាក់នោះខ្លួនស្គាល់តែពីរនាក់គឺឈ្មោះ ភារម្យ ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ កណ្តុរ ភេទប្រុស អាយុ ២១ឆ្នាំ និង ០៨នាក់ទៀត ខ្លួនមិនស្គាល់ទេ បានយកម៉ូតូ មួយគ្រឿងម៉ាកហុងដាសេ ១២៥ ពណ៌ក្រហមស៊េរីឆ្នាំ២០២០



Scanned with CamScanner

ពាក់ផ្លាកលេខ កំពង់ចាម 1Y-2872 គ្មានកន្ត្រក និងកញ្ចក់ទេ។ ដោយឈ្មោះ កណ្តុរ ជាអ្នកធ្វើដោយនិយាយថា អាអូនសុំផ្ញើម៉ូតូទុកនៅផ្ទះអូនឯងមួយផង ខ្លួនឆ្លើយថា បងយកទុកមុខផ្ទះសិនទៅ ឈ្មោះ កណ្តុរ បានយកម៉ូតូទុកមុខផ្ទះ និងផ្ញើដាវកែច្នៃចំនួន ពីរ និងកណ្តៀវ មួយផងដែរ។ បន្ទាប់មកពួកគាត់បានចេញទៅបាត់ទៅ ប៉ុន្តែខ្លួនមិនដឹងថា ពួកគាត់ទៅណាទេ។ លុះដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០នាទី មានកម្លាំងសមត្ថកិច្ច បានមកហៅខ្លួនទៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកថ្មីតែម្តង។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានសួរដេញដោលនាពេលសវនាការក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី និងអំណានចម្លើយជនជាប់ចោទផ្សេងៗទៀត និងក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង គឺអាចឱ្យ តំណាងអយ្យការកំណត់បានថា ពិតជាមាន **អំពើលួចមានស្ថានទម្ងន់ទោស** (កាប់យកម៉ូតូ) ដែលបង្កឡើងដោយឈ្មោះ [redacted] សុភារម្យ ភេទប្រុស អាយុ ១៧ឆ្នាំ,ឈ្មោះ [redacted] សិទ្ធិគុណ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សីហាគុន ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងគួ ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុ ១៧ឆ្នាំ,ឈ្មោះ [redacted] មីណា ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ [redacted] លីហួរ ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ ដែលបានយកកាំបិតប៉ុងតោ ទៅកាប់យកម៉ូតូរបស់ជនរងគ្រោះឈ្មោះ ឡុង គឹមលាង ពិតប្រាកដមែន ដោយប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដោយជនជាប់ចោទទាំងពីរនាក់ឈ្មោះ [redacted] សុភារម្យ និងឈ្មោះ [redacted] សីហាគុន គឺគាត់បានទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួន ពិតប្រាកដមែន។ ដោយឡែក ជនជាប់ចោទឈ្មោះ [redacted] **សិទ្ធិគុណ** នៅក្នុងពេលសវនាការគឺគាត់បានឆ្លើយបដិសេធថា គាត់មិនបានចូលរួមទេ និងពុំបានធ្វើដូចតំណាងអយ្យការចោទប្រកាន់ដែរ ប៉ុន្តែចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ និងឈ្មោះ [redacted] សីហាគុន គាត់បានឆ្លើយសារភាពថា មិត្តភក្តិរបស់ពួកគាត់ក្រោយពេលដែលកាប់ម៉ូតូបានហើយ គឺបានទូរស័ព្ទប្រាប់ពួកគេថា *កាប់ម៉ូតូបានមួយគ្រឿងហើយ* រួចពួកខ្លួនក៏សម្រេចចិត្តទៅច្បារអំពៅចាំ ដូចនឹងអ្វីដែលឈ្មោះ កណ្តុរ, គួ បានឆ្លើយថា ខ្លួនពិតជាបានឱ្យពួកគេចាំពិតមែន។ ពួកគាត់គឺមានភាពស្របគ្នា ដោយបានដឹងរឿងហេតុការណ៍ទាំងអស់ ប៉ុន្តែគាត់បែរជាមិនទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួននោះទេ។ ដូច្នេះ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ តំណាងអយ្យការស្នើសុំឱ្យតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទទាំងអស់ទៅតាមផ្លូវច្បាប់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សិទ្ធិគុណ** ធ្វើសេចក្តីសន្និដ្ឋានថា តាមអង្គហេតុ ការពិនិត្យសិក្សាសំណុំរឿង និងសួរដេញដោលនាពេលសវនាការ យល់ឃើញថា ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សិទ្ធិគុណ ខ្ញុំសូមបដិសេធទាំងស្រុងចំពោះការចោទប្រកាន់មកលើកូនក្តីខ្ញុំ ពីបទ លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ) ដោយហេតុថា ផ្អែកតាមពាក្យបណ្តឹងរបស់ដើមបណ្តឹងឈ្មោះ [redacted] គឹមលាង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ បានដាក់ពាក្យបណ្តឹង ដោយបានលើកឡើងថាមានមនុស្សគ្នា ០៧នាក់ បានមកកាប់ប្លន់យកម៉ូតូរបស់ខ្លួន បើអង្គហេតុគឺក្នុងរឿងនេះធ្វើការចោទប្រកាន់ឡើយ ព្រោះពេលនោះកូនក្តីខ្ញុំឈ្មោះ [redacted] សិទ្ធិគុណ មិននៅកន្លែងកើតហេតុ និងមិនបានប្រព្រឹត្តឡើយ ព្រោះខ្លួនកំពុងជិះម៉ូតូចាក់សាំងជាមួយឈ្មោះ ចាន់ សីហាគុន ដែលពួកគេអស់គ្នាដំបូងឡើយនាំគ្នាទៅមុខវត្តបុទុម ហើយក៏នាំគ្នាជិះមកវិញ និងបានបំបែកគ្នាទៅហើយ ព្រោះម៉ូតូកូនក្តីខ្ញុំជិះនោះអស់សាំងក៏ជិះទៅចាក់សាំង ចំណែក្រុមផ្សេងទៀតនាំគ្នាជិះបែកគ្នាមិនដឹងទៅណានោះទេ កូនក្តីខ្ញុំដឹងត្រឹមតែជិះមកនាំគ្នាអង្គុយលេងនៅមុខប៉ុស្តិ៍បាយ័នប៉ុណ្ណោះ។ ចំណុចនេះបើកូនក្តីខ្ញុំដឹង និងមានបំណងទៅប្លន់ជាមួយគ្នានៅ



Scanned with CamScanner

ចំណុចណានោះប្រាកដជាទៅតាមក្រោយហើយ តែជាក់ស្តែងកូនក្តីខ្ញុំពិតជាមិនដឹងមែន ទើបចេញពីចាក់សាំងក៏នាំគ្នាទៅកន្លែងផ្សេងពីក្រុមទាំងនោះ ហើយម្យ៉ាងក្នុងរឿងនេះ កូនក្តីខ្ញុំគ្រាន់តែជិះទៅតាមដោយសារគេនាំតែប៉ុណ្ណោះ មិនមែនខ្លួនជាអ្នកបើកម៉ូតូដោយផ្ទាល់នោះទេ។ ហើយចំពោះ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ដែលបានធ្វើឡើងកន្លងមកក៏ឃើញថា មិនមានការចូលរួមប្រព្រឹត្តសកម្មភាពកាប់ប្លន់យកម៉ូតូរបស់កូនក្តីខ្ញុំបាទនៅពេលកើតហេតុដែរ ដូចមានការឆ្លើយបញ្ជាក់របស់ឈ្មោះ [redacted] សីហាតុន និងឈ្មោះ [redacted] សុភារម្យ បានសារភាពការប្លន់យកម៉ូតូ ទាំងបីលើកកន្លងមកគឺរាល់សកម្មភាពទាំងបីលើកនេះមិនដែលមានវត្តមានកូនក្តីខ្ញុំចូលរួមនោះទេ។ ផ្អែកតាមចម្លើយរបស់កូនក្តីឈ្មោះ និច សិទ្ធិគុណ នៅចំពោះមុខតំណាងអយ្យការ និងចំពោះមុខចៅក្រមស៊ើបសួរ ឃើញថា កូនក្តីខ្ញុំសូមបដិសេធគ្រង់ចំណុចនេះឈ្មោះ គួរ និងឈ្មោះ កណ្តុរ ថាបបួលខ្លួន និងបក្ខពួកទៅផាក់ និងកាប់យកម៉ូតូគេគឺក្នុងរឿងនេះ គឺឈ្មោះ តន់ បានបបួលខ្លួនទៅវ៉ាយឈ្មោះ ពេជ្រ ជាសាក្សីថ្មីរបស់សង្សារចាស់ខ្លួន ក្រៅពីនោះខ្លួនមិនដឹងទេ។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ខ្លួនបានទៅផឹកកាហ្វេ ឈ្មោះ តន់ ហៅខ្លួនឱ្យជិះម៉ូតូទៅជាមួយទៅលេងបុកប៊ីយ៉ែរ ក៏មានឈ្មោះ គួ តេមកឈ្មោះ តន់ ឱ្យទៅជុំគ្នា ដើម្បីទៅរកគូសត្រូវនៅម្តុំវត្តបុទុមរកសត្រូវមិនឃើញក៏នាំគ្នាមកប៉ុស្តិ៍បាយ៉ន បន្ទាប់មកឈ្មោះ កណ្តុរ ថាតោះ តែខ្លួនមិនដឹងថាទៅធ្វើអ្វីទេបើដឹងថាទៅប្លន់ម៉ូតូគេ ក៏ខ្លួនខ្ញុំមិនទៅទេ គឺចេញពីបាយ៉ន់ទៅកៀនស្វាយ ចូលចាក់សាំងមានម៉ូតូ២គ្រឿងចំណែក ០៣គ្រឿងទៀតជិះទៅបាត់ មិនដឹងគេទៅណាធ្វើអ្វីទេ ទើបពួកខ្លួនទៅចាំនៅកៀនស្វាយកន្លែងលក់ដូរក៏ស្រាប់តែឈ្មោះ គួ បានទូរស័ព្ទមកឈ្មោះ ភារម្យ ថាបានម៉ូតូ ០១គ្រឿង ក្រោយមកក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។ បើដឹងថាពួកគាត់ ជាចោរប្លន់ម៉ូតូគេខ្លួនមិនជិះទៅជាមួយឡើយ។ ផ្អែកតាមចម្លើយសារភាពរបស់ឈ្មោះ [redacted] សីហាតុន និងឈ្មោះ [redacted] សុភារម្យ បានសារភាពថាចំពោះមុខសមត្ថកិច្ច (របាយការណ៍របស់អធិការនគរបាលស្រុកកៀនស្វាយឈ្មោះ [redacted] សំណាង) ធ្លាប់កាប់យកម៉ូតូចំនួន ០៣លើក លើកទី១ ខែមីនា ឆ្នាំ២០២២ មានខ្លួន, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ, [redacted] ម៉េងគួ, ម៉ៅ សុភារម្យ បានធ្វើសកម្មភាពកាប់យកម៉ូតូនៅក្រុងតាខ្មៅ តែមិនបានសម្រេច។ លើកទី២ នៅថ្ងៃមិនចាំ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ៣និង៣០នាទី ខ្លួនរួមជាមួយឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ, [redacted] ម៉េងគួ, [redacted] សុភារម្យ បានធ្វើសកម្មភាពកាប់ផាក់យកម៉ូតូ នៅក្រុងតាខ្មៅ តែមិនបានសម្រេច។ លើកទី៣ នៅភូមិកោះចិន ត្រូវសមត្ថកិច្ចឃាត់ខ្លួនបាន។ ផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ (បានឆ្លើយប្រហាក់ប្រហែលគ្នានៅដំណាក់កាលស៊ើបសួរ) ថា៖ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ៩យប់ ពេលជុំគ្នានៅផ្ទះឈ្មោះ ណើ ពេលនោះឈ្មោះ ម៉េងគួ និងសុភារម្យ នាំគ្នាទៅកាប់ពួកលៀសហាលនៅមុខវត្តបុទុមពេលទៅដល់ឃើញមានសមត្ថកិច្ចក៏ត្រឡប់មកវិញនៅប៉ុស្តិ៍បាយ៉ន ពេលធ្វើដំណើរជិះម៉ូតូ ៥គ្រឿង មកវិញ បាន០២ម៉ូតូ មិនដឹងទៅណា។ ដល់ម៉ោង ១ឈានចូលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ មានឈ្មោះ ជាតិ, គួ, ស៊ុ, មីណា ឈ្មោះ កណ្តុរ និងខ្លួន បានធ្វើសកម្មភាពកាប់ប្លន់ម៉ូតូពីមនុស្សប្រុសម្នាក់ជិះម៉ូតូស្គូពី ស៊េរីឆ្នាំ២០២១ ពេលប្លន់បានក៏យកម៉ូតូទៅលក់បាន ៩០០ដុល្លារ ក៏នាំគ្នាទៅលេងកំពត ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ យោងតាមចម្លើយខាងលើរបស់ឈ្មោះ [redacted] សិទ្ធិគុណ (កូនក្តីយើងខ្ញុំ) បានឆ្លើយបដិសេធចំពោះការមិនបានដឹង និងមិនបានចូលរួមអំពីការប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស(កាប់យកម៉ូតូ) នៃសំណុំរឿងនេះ ដោយប្រៀបធៀបទៅនឹងអង្គហេតុ ក៏ដូចជាចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហាតុន, [redacted] សុភារម្យ នៅមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ នៅដំណាក់កាលចៅក្រមស៊ើបសួរ ឃើញថា កូនក្តីខ្ញុំពិតជាមិនបានដឹង



Scanned with CamScanner

និងមិនបានចូលរួមគំនិតអំពីការធ្វើសកម្មភាព ប្លន់កាប់យកម៉ូតូ ពិតប្រាកដមែន ហើយចំពោះសកម្មភាពប្លន់កន្លងមកក៏ពុំដែលមានវត្តមានកូនក្តីខ្ញុំចូលរួមផងដែរ។ នៅក្នុងរឿងនេះ កូនក្តីខ្ញុំគ្រាន់តែជិះដោយសារ និងទៅតាមគេប៉ុណ្ណោះ ពុំស្តែងឱ្យឃើញពីចេតនាក្នុងការចូលរួមធ្វើសកម្មភាពប្លន់កាប់យកម៉ូតូនោះទេ។ ចំពោះតំណាងអយ្យការធ្វើការចោទប្រកាន់កូនក្តីខ្ញុំតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៤៣ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២២ ដោយដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោស(កាប់យកម៉ូតូ) ឃើញថា កូនក្តីខ្ញុំបាទពិតជាទទួលរងនូវភាពអយុត្តិធម៌ជាខ្លាំង ព្រោះថាចំពោះចម្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ ដោយខ្លួនជាអនីតិជនមានស្មារតីភ័យខ្លាចចម្លើយមានចំណុចមួយចំនួន ខ្លួនសូមបដិសេធ តាមរយៈចម្លើយនៅចំពោះមុខតំណាងអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ដែលមានមេធាវីអមធ្វើឱ្យមានស្មារតីល្អក្នុងការឆ្លើយបំភ្លឺចំពោះមុខតុលាការ ដោយខ្លួនបានបដិសេធចំពោះថាខ្លួនចូលរួមការប្លន់កាប់យកម៉ូតូ ដែលខ្លួនពុំបានដឹង ពុំបានចូលរួមចំពោះអំពើទាំងនោះឡើយ ហើយម្យ៉ាងបើផ្អែកតាមចម្លើយសាក្សីក៏ដូចជាអង្គហេតុ និងចម្លើយជនជាប់ចោទផ្សេងទៀត ឃើញថា ចាប់តាំងពីផ្តើមគំនិតធ្វើសកម្មភាពរហូតដល់អំឡុងពេលកើតហេតុ និងបញ្ចប់សកម្មភាព គឺពុំមានការចូលរួមដោយកូនក្តីខ្ញុំបាទឈ្មោះ និច សិទ្ធិគុណ ឡើយ។ យោងតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌខាងលើ និងអង្គហេតុក៏ដូចជាចម្លើយរបស់ជនជាប់ចោទក្នុងសំណុំរឿងនេះ ឃើញថា កូនក្តីខ្ញុំបាទ ពុំមានធាតុផ្សំណាមួយដែលបានប្រព្រឹត្តចូលក្នុងអំពើល្មើសនៃមាត្រាខាងលើទេ ព្រោះថាចំពោះចាប់តាំងពីផ្តើមធ្វើសកម្មភាពពីដំបូងរហូតដល់បញ្ចប់សកម្មភាព កូនក្តីខ្ញុំពុំបានដឹងអំពីអំពើ កាប់យកម៉ូតូជនរងគ្រោះនោះទេ ជាក់ស្តែងកូនក្តីខ្ញុំក៏ពុំបានចូលរួមក្នុងសកម្មភាពកាប់ប្លន់នេះដែរ ទើបតែដឹងនៅពេលដែលមានគេប្រាប់ក្រោយពេលដែលបទល្មើសបានប្រព្រឹត្តរួច និងសម្រេចទៅហើយ។ ហើយម្យ៉ាងចំពោះម៉ូតូដែលប្លន់បាននោះ ក៏ពុំមានពាក់ព័ន្ធនឹងផលប្រយោជន៍ដល់កូនក្តីខ្ញុំបាទឡើយ ដោយជាក់ស្តែងជនជាប់ចោទឈ្មោះ គូ និងឈ្មោះ ជាតិ បានយកម៉ូតូទៅលក់ហើយប្រាក់ដែលបានពីការលក់នោះក៏យកទៅប្រើប្រាស់ជាប្រយោជន៍របស់ពួកគេទាំងអស់ពុំមានពាក់ព័ន្ធនឹងកូនក្តីខ្លួនឡើយ។ យោងតាមអង្គហេតុ អង្គច្បាប់ ផ្អែកតាមចម្លើយសាក្សី និងចម្លើយជនជាប់ចោទ ឃើញថា កូនក្តីខ្ញុំបាទជាអនីតិជនមានអាយុ ១៦ឆ្នាំ មានភាពទន់ខ្សោយទាំងផ្លូវកាយ ផ្លូវចិត្ត និងមានកម្រិតវប្បធម៌ទាប ត្រឹមថ្នាក់ទី៥ ប៉ុណ្ណោះ ពុំមានសមត្ថភាពក្នុងការប្រព្រឹត្តបទល្មើសទាំងនេះឡើយ។ កូនក្តីខ្ញុំពុំដែលប្រព្រឹត្តអំពើផ្ទុយច្បាប់ពិសេសពុំមានសារធាតុញៀនក្នុងខ្លួននោះទេ។ ចាប់ទាំងពីផ្តើមសកម្មភាពរហូតបញ្ចប់សកម្មភាពឃើញថា ពុំមានពាក់ព័ន្ធចូលរួមប្រព្រឹត្ត ឬសមគំនិតដោយកូនក្តីខ្ញុំ ដែលបង្ហាញឱ្យឃើញថា កូនក្តីខ្ញុំមានចេតនាទុច្ចរិតក្នុងការធ្វើអំពើល្មើសនេះឡើយ។ ចំពោះបទល្មើសខាងលើក៏ពុំមានផ្តល់ផលប្រយោជន៍ណាមួយដល់កូនក្តីខ្ញុំបាទនោះទេ។ កូនក្តីខ្ញុំជាជនសុចរិត ស្លូតត្រង់ ពុំដែលបង្ករបញ្ហាដល់គ្រួសារ មូលដ្ឋាន ក៏ពុំដែលប្រព្រឹត្តបទល្មើសពីមុនមកឡើយ ដូចមានលិខិតបញ្ជាក់អាកប្បកិរិយាមាយាទ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ របស់មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលតាខ្មៅដាក់ជូនតុលាការកន្លងមក។ ក្នុងនាមជាខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សិទ្ធិគុណ យល់ឃើញថា ក្នុងរឿងនេះពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទឡើយ។ យោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ចេតនាប្រព្រឹត្តបទល្មើស កថាខណ្ឌទី១ ចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កថាខណ្ឌទី៥ ចែងថា *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*។ ដូចនេះ ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សិទ្ធិគុណ សូមសំណូមពរ ក្រុមប្រឹក្សាជំនុំជម្រះ

មេត្តាជួយរកយុត្តិធម៌ដល់កូនក្តីខ្ញុំ ដោយសុំឱ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងអំពើខាងលើ និងធ្វើការដោះលែងកូនក្តីខ្ញុំឱ្យមានសេរីភាពវិញ ចាប់ពីពេលនេះតទៅ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សិទ្ធគុណ និងឈ្មោះ [redacted] សីហាតុន បានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះសេចក្តីសន្និដ្ឋានលើកូនក្តីឈ្មោះ [redacted] សិទ្ធគុណ ខ្ញុំបាទសូមរក្សាទៅតាមសេចក្តីសន្និដ្ឋានរបស់សហភាគា។ ឆ្លងកាត់តាមការសួរដេញដោលនាពេលសវនាការ តាមចម្លើយរបស់ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ និងឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត បានឆ្លើយថា ជនជាប់ចោទទាំងបីនាក់នេះ ដែលជាកូនក្តីរបស់ខ្ញុំបាទ គឺមិនបានចូលរួមធ្វើសកម្មភាពនោះទេ ដោយម៉ូតូពួកគាត់អស់សាំង និងបានចូលចាក់សាំងម៉ូតូ។ កូនក្តីរបស់ខ្ញុំបាទ គឺជាអនីតិជន ដែលងាយស្រួលក្នុងការអូសទាញរបស់មិត្តភក្តិ ដោយមិនបានគិតពិចារណាបានវែងឆ្ងាយនោះទេ។ ខ្ញុំបាទស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់នូវស្ថានសម្រាលទោសឱ្យកូនក្តីខ្ញុំ តាមមាត្រា ៩៣ មាត្រា ៩៤ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហួរ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ឃើញថា ដោយសារតែកូនក្តីរបស់ខ្ញុំ មិនបានមានវត្តមាននាពេលសវនាការនេះ ដោយសារមានការឃុំខ្លួននៅក្នុងសំណុំរឿងផ្សេងទៀត ប៉ុន្តែមានចម្លើយរបស់កូនក្តីខ្ញុំនៅក្នុងសំណុំរឿងរួចហើយ ដូច្នេះ ខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណានូវចម្លើយរបស់ពួកគាត់ និងអាយុរបស់ពួកគាត់ ដោយសារតែគាត់នៅក្មេង។ ដូច្នេះ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាសម្រេចពិចារណាទៅតាមនីតិវិធីច្បាប់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហួរ បានធ្វើសេចក្តីសន្និដ្ឋានថា ដោយសារតែសំណុំរឿង និងការស្រាវជ្រាវកន្លងមក គឺពុំបានឃើញភស្តុតាងគ្រប់គ្រាន់ និងឈានដល់ការដាក់បន្ទុកផ្តន្ទាទោសកូនក្តីខ្ញុំទេ។ ដូច្នេះ ខ្ញុំស្នើសុំឱ្យពិចារណាអង្គច្បាប់ និង វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ និងសំណូមពរសុំឱ្យតុលាការពិចារណាសម្រេចទៅតាមច្បាប់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងគួ បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងសំណុំរឿងនេះ នាងខ្ញុំសង្កេតឃើញថា ជនជាប់ចោទទាំងបីរូប ដែលបានឆ្លើយនៅចំពោះមុខអង្គសវនាការ ឃើញថាមិនមានពាក់ព័ន្ធចម្លើយណាមួយដាក់បន្ទុកទៅលើកូនក្តីនាងខ្ញុំឈ្មោះ [redacted] ម៉េងគួ ទេ ដូចចម្លើយជនជាប់ចោទបានឆ្លើយថា ឈ្មោះ គួ មិនមែនឈ្មោះ [redacted] ម៉េងគួ នោះទេ ឃើញថា មិនមានចម្លើយណាមួយដែលបញ្ជាក់ថា កូនក្តីខ្ញុំ [redacted] ម៉េងគួ បានពាក់ព័ន្ធ ឬដាក់បន្ទុកនៅលើរឿងក្តីនោះ ឬបានចូលរួមសកម្មភាពជិះម៉ូតូកាប់គេ ឬធ្វើអ្វីមួយដែលដាក់បន្ទុកលើរឿងនេះទេ។ ឃើញថា មិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើកូនក្តីខ្ញុំ [redacted] ម៉េងគួ នោះទេ។ ឈ្មោះ [redacted] ម៉េងគួ គាត់មានសាវតាជាតិគ្រប់គ្រាន់ និងមិនមានចម្លើយណាមួយ ឬចម្លើយរបស់ជនជាប់ចោទទាំងបីនាក់នេះ បានឆ្លើយថា ឈ្មោះ [redacted] ម៉េងគួ នោះបានចូលរួមសកម្មភាពប្រព្រឹត្តនោះទេ។ កូនក្តីនាងខ្ញុំនៅក្រៅឃុំ និងមិនមានធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់មកលើកូនក្តីនាងខ្ញុំ វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់កូនក្តីនាងខ្ញុំ។ ដូច្នេះ នាងខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សា



Scanned with CamScanner

ជំនុំជម្រះមេត្តាសម្រេចលើកលែងចោទប្រកាន់លើកូនក្តីនាងខ្ញុំ និងបញ្ឈប់ដីកាចាប់ខ្លួនកូនក្តីនាងខ្ញុំផង ដើម្បីកុំឱ្យមានការចាប់ខ្លួនកូនក្តីនាងខ្ញុំដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍កូនក្តីនាងខ្ញុំទៅតាមផ្លូវច្បាប់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិគុណ ៖ ខ្ញុំសំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ ពីព្រោះខ្ញុំបាទមិនបានធ្វើអ្វីនោះទេ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហាតុន ៖ ខ្ញុំបាទស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ៖ ខ្ញុំស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សារួចហើយ
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកណ្តាល**

**យល់ឃើញថា**

តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ របស់ចៅក្រមស៊ើបសួរលេខៈ៩៧៥ ដកជស ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សុភារម្យ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សិទ្ធិគុណ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សីហាតុន ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងគួ ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] មីណា ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] លីហួរ ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទៈ **លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ)** ប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភារម្យ បានឆ្លើយថា ខ្លួនពិតជាបានចូលរួមធ្វើសកម្មភាពប្លន់យកម៉ូតូគេសរុបចំនួនបីលើកមកហើយ តែលើកទីមួយ និងទីពីរ មិនបានទេ ដោយលើកទីបី នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ពីរ យប់ មានគ្នាចំនួនដប់នាក់ មានឈ្មោះ [redacted] លីហួរ , ឈ្មោះ កណ្តុរ , ឈ្មោះ អាតុង, ឈ្មោះ គុណ, ឈ្មោះ អាគួ, ឈ្មោះ ស្វិត, ឈ្មោះ ជាតិ, ឈ្មោះ ស៊ី, ឈ្មោះ មីណា និងខ្លួន។ ពេលធ្វើសកម្មភាពប្លន់ម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ពណ៌ស នោះ ឈ្មោះ ស្វិត , ឈ្មោះ កណ្តុរ, ឈ្មោះ គួ, ឈ្មោះ ជាតិ, ឈ្មោះ ស៊ី និងឈ្មោះ អាមីណា ដោយខ្លួនពុំបាននៅតាមគ្នាប្រាំមួយនាក់នេះទេ ព្រោះម៉ូតូខ្លួនចូលចាក់សាំងពីរគ្រឿង។ ចំពោះម៉ូតូខ្លួនពីរគ្រឿងចាក់សាំងមានឈ្មោះ [redacted] ហួរ ជិះម៉ូតូពីក្រោយខ្លួន ម៉ាក សង់ សេ១២៥ ពណ៌ខ្មៅ ជារបស់ម្តាយខ្លួន និងម៉ូតូមួយគ្រឿងទៀតជារបស់ឈ្មោះ តុន និងឈ្មោះ



Scanned with CamScanner

គុណ ជិះពីក្រោយនៅស្រុកកៀនស្វាយ រកគ្នាខ្លួនប្រាំមួយនាក់មិនឃើញ ក៏ឈប់ម៉ូតូនៅកន្លែងគេលក់ដូរ ហើយមានគ្នាខ្លួនឈ្មោះ គូ ទូរស័ព្ទមកច្បារអំពៅ ក៏ខ្លួនជិះមកម្តុំបឹងស្នោ ក៏សមត្ថកិច្ចមកឃាត់ពួកខ្លួន មាន ឈ្មោះ គុណ , ឈ្មោះ គុន និងខ្លួន។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សិទ្ធិគុណ** បានឆ្លើយថា កន្លងមកខ្លួនពិតដែលធ្វើសកម្មភាព ប្លន់ម៉ូតូរបស់គេទេ ហើយនៅថ្ងៃកើតហេតុទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោងប្រហែល ០៣ និង ៣០នាទី ទៀប ភ្លឺ ត្រូវសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ គុន, ឈ្មោះ ភារម្យ និងឈ្មោះ [redacted]ហួរ រត់គេខ្លួន ពេលពួកខ្លួនបួននាក់ជិះម៉ូតូ ពីរគ្រឿង ត្រឡប់មកផ្ទះ ឃាត់ខ្លួននៅម្តុំជិតស្ពានច្បារអំពៅ បានដកហូតម៉ូតូតពីរគ្រឿង ទូរស័ព្ទខ្លួនមួយគ្រឿង និងគ្នាខ្លួនពីរនាក់ទៀត ព្រមទាំងទូរស័ព្ទម្នាក់មួយគ្រឿងដែរ។ នៅម៉ោង ០៤រសៀល ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០២២ ខ្លួនដើរទៅផឹកកាហ្វេ លុះដល់ម៉ោង ០៦ល្ងាច ឈ្មោះ [redacted] ហៅ ខ្លួនជិះម៉ូតូជាមួយវាទៅកន្លែងបុក ប៊ីយ៉ែ ចេញពីបុកប៊ីយ៉ែ ទៅផ្ទះរបស់ឈ្មោះ នុន អង្គុយលេង ក៏មានឈ្មោះ គូ ទូរស័ព្ទហៅខ្លួន ខ្លួនក៏ជិះម៉ូតូ ជាមួយឈ្មោះ គុន និងឈ្មោះ ជាតិ ជិះម៉ូតូមួយផ្សេង ទៅច្បារអំពៅ ទៅផ្ទះរបស់ឈ្មោះ នី ក៏ជុំគ្នាណាត់នៅ ភ្នំពេញម្តុំវត្តបុទុម រកគូសត្រូវមិនឃើញ ក៏មកប៉ុស្តិ៍បាយ័ន ក៏មានឈ្មោះ គូ, ឈ្មោះ កណ្តុរ ថាទៅកៀនស្វាយ ខ្លួនមិនដឹងថាទៅធ្វើអ្វីទេ បើដឹងថាទៅប្លន់ម៉ូតូគេខ្លួនមិនទៅទេ។ ហើយចេញពីបាយ័នទៅកៀនស្វាយ បាន ពាក់កណ្តាលផ្លូវម៉ូតូពីរគ្រឿងចូលចាក់សាំងម៉ូតូមួយគ្រឿង ខ្លួនជិះជាមួយឈ្មះ គុន និងម៉ូតូមួយគ្រឿងទៀត ឈ្មោះ ភារម្យ ឌុបឈ្មោះ ហួរ ហើយម៉ូតូបីគ្រឿងទៀតជិះទៅបាត់ មិនដឹងគេទៅណាធ្វើអ្វីទេ លុះចាក់សាំងរួច ម៉ូតូពួកខ្លួនពីរគ្រឿងជិះតាមក្រោយរត់មិនទាន់ និងរកគេមិនឃើញ ក៏ត្រឡប់មកចាំនៅកៀនស្វាយ នៅកន្លែង លក់ដូរ ក៏មានឈ្មោះ គូ ទូរស័ព្ទមកឈ្មោះ ភារម្យ ថាបានម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ហើយ ឈ្មោះ គូ បានប្រាប់ឱ្យពួកខ្លួនជិះម៉ូតូពីរគ្រឿងមកស្ពានច្បារអំពៅ ពេលត្រឡប់មកជិតស្ពានច្បារអំពៅ ត្រូវ សមត្ថកិច្ចឃាត់ខ្លួន បានមនុស្ស បីនាក់ និងម៉ូតូបីគ្រឿង ដោយឈ្មោះ ហួរ បានរត់គេចខ្លួន។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សីហគុន** បានឆ្លើយថា កន្លងមកខ្លួនធ្លាប់ចូលរួម ធ្វើសកម្ម ភាពប្លន់ម៉ូតូគេពីរលើកមកហើយ តែពុំបានសម្រេច យកម៉ូតូគេបានទេ គឺលើកទីមួយ និងលើកទីពីរ នៅស្រុក ស្អាង មិនចាំថ្ងៃខែទេ ក្នុងឆ្នាំ២០២២ និងលើកទីបី ធ្វើដំណើរនៅតាមផ្លូវកៀនស្វាយ ម៉ូតូអស់សាំង ចូលចាក់ សាំងម៉ូតូពីរគ្រឿង និងម៉ូតូបីគ្រឿងទៅហួស លុះចាក់សាំងរួច ជិះទៅតាមក្រោយ តែពុំទាន់ម៉ូតូបីគ្រឿងនោះទេ ហើយខ្លួនក៏ពុំដឹង ម៉ូតូបីគ្រឿងនោះទៅណាដែរ។ បន្ទាប់មកឈ្មោះ គូ បានទូរស័ព្ទមកឈ្មោះ ភារម្យ ឱ្យទៅចាំ នៅស្ពានច្បារអំពៅ ពេលនោះម៉ូតូពួកខ្លួនពីរគ្រឿងជិះត្រឡប់មកវិញ ដល់ម្តុំបឹងស្នោក៏ត្រូវសមត្ថកិច្ចឃាត់បាន មនុស្សបីនាក់ មានខ្លួន , ឈ្មោះ គុណ និងឈ្មោះ ភារម្យ តែឈ្មោះ ហួរ បានរត់គេចខ្លួនបាត់។ ខ្លួនមិនបានដឹង រឿងអ្វីនោះទេ ខ្លួនមិនបានចូលរួមសកម្មភាពជាមួយពួកគេនោះទេ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់ថា ហៅ ស្វិត** បានឆ្លើយថា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ប្រហែលម៉ោង ២១យប់ ពួកខ្លួនបានជុំគ្នានៅផ្ទះរបស់ឈ្មោះ ណី ភេទប្រុស មានគ្នា ១០នាក់ ពេលនោះឈ្មោះ គូ និងឈ្មោះ ភារម្យ បានទៅយកដាវនៅផ្ទះរបស់ឈ្មោះ ភារម្យ ប្រហែល ប្រាំបីដើម គោលបំណងទៅកាប់ពួកក្រុមលៀសហាល នៅមុខវត្តបុទុម ពេលទៅដល់វិមានឯករាជ្យ ក៏ឃើញមានសមត្ថ កិច្ច ក៏ត្រឡប់មកជុំគ្នានៅស្ថានីយទូរទស្សន៍បាយ័ន លុះដល់ម៉ោង ១២យប់ ពួកខ្លួនជិះម៉ូតូទៅកៀនស្វាយ ក្នុងគោលបំណងដើម្បីប្លន់ ពេលធ្វើដំណើរទៅជិះម៉ូតូប្រាំគ្រឿង ហើយមិត្តភក្តិខ្លួន ពីរម៉ូតូមិនដឹងបាត់ទៅណា ។ រហូតដល់ម៉ោងប្រហែល ០១ និង ៣០នាទី ឈានចូលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ ជាតិ, ឈ្មោះ គូ, ឈ្មោះ ស៊ី, ឈ្មោះ មីណា, ឈ្មោះ កណ្តុរ និងខ្លួន បានធ្វើសកម្មភាពកាប់ប្លន់ម៉ូតូពីមនុស្សប្រុសម្នាក់ជិះម៉ូតូ

HONDA SCOOPY សេរីឆ្នាំ២០២១ ពេលនោះឈ្មោះ កណ្ដុរ បានកាប់បុរសនោះចំនួនមួយកាំបិត ហើយដួល បន្ទាប់មកឈ្មោះ ជាតិ ក៏បានចុះទៅកាប់ជាច្រើនកាំបិតទៀតមិនដឹងត្រូវកន្លែងណាទេ បន្ទាប់មកឈ្មោះ ជាតិ ក៏បានលើកម៉ូតូជិះចេញ ឈ្មោះ គូ បានប្រាប់ពួកខ្លួនឱ្យទៅចាំនៅផ្សារឃ្លាំងរំសេវ ទៅដល់ហាងលក់បានចំនួន ៩០០ (ប្រាំបួនរយដុល្លារអាមេរិក) ប៉ុន្តែខ្លួនមិនដឹងថាវាលក់នៅហាងណាទេ បន្ទាប់មក ពួកខ្លួនបានទៅលេងខេត្តកំពត លុះដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ម៉េងហាក់ ហៅ កណ្ដុរ** បានឆ្លើយថា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ពួកខ្លួនមានគ្នា ប្រាំនាក់ មានឈ្មោះ គូ ភេទប្រុស, ឈ្មោះ ស្វិត ភេទប្រុស, ឈ្មោះ ជាតិ ភេទប្រុស, ឈ្មោះ ស៊ី ភេទប្រុស បានទៅជុំគ្នានៅផ្ទះរបស់ឈ្មោះ ណី ដោយមានគ្នា ១០នាក់ និងម៉ូតូប្រាំគ្រឿង ពេលជុំគ្នាឈ្មោះ គូ និងឈ្មោះ ភារម្យ បានទៅយកដាវ និងកាំបិតចំនួន ប្រាំបីដើម ដោយឈ្មោះ គូ បបួលពួកខ្លួន ទៅកាប់អ្នកលក់លៀសហាល ពេលទៅឃើញសមត្ថកិច្ច ពួកខ្លួនក៏នាំគ្នាទៅស្ថានីយប៉ុស្តិ៍បាយ៉ន ដល់ម៉ោងប្រហែល មួយរំលងអាធ្រាតឈានចូលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ គូ បបួលពួកខ្លួនទៅកាប់គេនៅស្រុកកៀនស្វាយ ដោយពេលនោះខ្លួនជិះជាមួយឈ្មោះ គូ, ឈ្មោះ ស្វិត ជិះម៉ូតូជាមួយឈ្មោះ ជាតិ, ឈ្មោះ មីណា ជិះជាមួយឈ្មោះ ស៊ី, ឈ្មោះ ហ្សូ ជិះជាមួយឈ្មោះ ភារម្យ និងឈ្មោះ តុន ជិះជាមួយឈ្មោះ គុណ។ ពេលដល់ស្រុកកៀនស្វាយ ស្រាប់តែម៉ូតូរបស់ឈ្មោះ ហ្សូ និងឈ្មោះ តុន បានអស់សាំង រួចពួកខ្លួនជិះម៉ូតូបីគ្រឿង ទៅដល់ចំណុចផ្សារគគីរក៏ឃើញមនុស្សប្រុសម្នាក់ជិះម៉ូតូម៉ាក HONDA SCOOPY ពណ៌ស សេរីឆ្នាំ២០២១ ពួកខ្លួនក៏ជិះតាមដល់វត្តកោះ ខ្លួនក៏បានកាប់បុរសម្នាក់នោះ មួយកាំបិតតាំងតោ បន្ទាប់មកឈ្មោះ ជាតិ និងឈ្មោះ ស្វិត បានជិះដេញបុរសម្នាក់នោះដល់មុខវត្ត បុរសម្នាក់នោះក៏ដួលម៉ូតូ ហើយឈ្មោះ ជាតិ បានកាប់ថែមជាច្រើនកាំបិត ហើយឈ្មោះ ជាតិ បានលើកម៉ូតូបុរសម្នាក់នោះជិះទៅបាត់ រួចឈ្មោះ គូ បានប្រាប់ឱ្យខ្លួនទៅចាំនៅកន្លែងលក់ម៉ូតូនៅឃ្លាំងរំសេវ ដោយឈ្មោះ ជាតិ និងឈ្មោះ គូ លក់ម៉ូតូបានចំនួន ៩០០ (ប្រាំបួនរយដុល្លារអាមេរិក) រួចពួកខ្លួនបានទៅលេងខេត្តកំពត លុះដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួន និងបក្ខពួកធ្លាប់ធ្វើសកម្មភាពកាប់ប្លន់នៅស្រុកស្អាង ប៉ុន្តែមិនបានសម្រេច ទើបតែធ្វើសកម្មភាពនៅស្រុកកៀនស្វាយបានសម្រេច។

-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមលាង** បានឆ្លើយថា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ០១ និង ៣០នាទី កណ្ដាលអាធ្រាតខ្លួនបានជិះម៉ូតូម៉ាក ស្កុបពី ពណ៌ស សេរីឆ្នាំ២០២១ ពាក់ផ្លាកលេខ កណ្ដាល 1AM-6603 ចេញពីផ្ទះរបស់ឈ្មោះ [redacted] ឆាយ ភេទប្រុស នៅភូមិកោះទៀវ ឃុំគគីរ ស្រុកៀនស្វាយ ខេត្តកណ្ដាល ដើម្បីទៅទិញគុយទាវនៅចំណុចមុខមន្ទីរពេទ្យបង្អែកស្រុកកៀនស្វាយ ខ្លួនក៏ឈប់ម៉ូតូទិញគុយទាវទិញរួចហើយ ខ្លួនក៏ជិះម៉ូតូទៅផ្ទះរបស់ឈ្មោះ [redacted] ឆាយ វិញ។ ជិះម៉ូតូដល់មុខខ្លោងទ្វារវត្តកោះ ស្រាប់តែមានជនមិនស្គាល់ ជិះម៉ូតូ បីគ្រឿង ម៉ាកហុងដា ១២៥ ចំនួន ពីរគ្រឿង និងម៉ូតូ មួយគ្រឿង ម៉ាកស្កុបពី ពណ៌ខ្មៅ មិនចាំសេរី ដោយមានគ្នា ០៧នាក់ បានជិះម៉ូតូមកជិតខ្លួន រួចបានជាក់ម៉ូតូខ្លួនបណ្ដាលឱ្យដួល ហើយជនមិនស្គាល់បានយកកាំបិតប៉ុងតោមកកាប់ចំមូក មួយកាំបិត បន្ទាប់មកខ្លួនបានប្រតាយប្រតប់ជាមួយជនមិនស្គាល់មិនឱ្យយកម៉ូតូទៅ រួចក៏មានគ្នាវាមកកាប់ខ្លួនចំនួនពីរប៉ុងតោទៀត ចំពីក្រោយក្បាល បណ្ដាលឱ្យមានរបួសចេញឈាម ពេលនោះជនមិនស្គាល់បានលើកម៉ូតូរបស់ខ្លួនជិះទៅខាងភ្នំពេញបាត់ទៅ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] **វ៉ារី ហៅ តី** បានឆ្លើយថា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០៣ និង ២០នាទី ខ្លួនកំពុងសំរាកនៅផ្ទះ ថៅកែប្ដី បានមកប្រាប់ថា ប្ដីខ្លួនត្រូវចោរកាប់ចំនួន ពីរកាំបិត



Scanned with CamScanner

ចំក្បាល និងខ្នងយកម៉ូតូ តែយកមិនបាន ពេលខ្លួនមកមើលប្តីនៅមន្ទីរពេទ្យបង្អែកស្រុកកៀនស្វាយ ប្តីខ្លួនបានប្រាប់ថា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ០២ និង ១០នាទី គាត់កំពុងជិះម៉ូតូតាមផ្លូវ ស្រាប់តែជនសង្ស័យចំនួន បីម៉ូតូ មិនដឹងប៉ុន្មាននាក់ទេ កាប់ចំក្បាលខ្នង តែយកម៉ូតូមិនបានទេ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សារ៉េត បានឆ្លើយថា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២២ ម៉ោង ២១ និង ៣០នាទី ខ្លួនកំពុងអង្គុយលេងមុខផ្ទះជាមួយប្អូនប្រុសឈ្មោះ [redacted] លីនណា ភេទប្រុស ស្រាប់តែម៉ូតូចំនួន ០៧ម៉ូតូ ម៉ាកហុងដារសេ ១២៥ មានគ្នា ១០នាក់ ក្នុងចំណោម ១០នាក់នោះខ្លួនស្គាល់តែពីរនាក់គឺឈ្មោះ ភារម្យ ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ កណ្តុរ ភេទប្រុស អាយុ ២១ឆ្នាំ និង ០៨នាក់ទៀត ខ្លួនមិនស្គាល់ទេ បានយកម៉ូតូ មួយគ្រឿងម៉ាកហុងដាសេ ១២៥ ពណ៌ក្រហមស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខ កំពង់ចាម 1Y-2872 គ្មានកន្ត្រក និងកញ្ចក់ទេ។ ដោយឈ្មោះ កណ្តុរ ជាអ្នកផ្ញើដោយនិយាយថា អាអូនសុំផ្ញើម៉ូតូទុកនៅផ្ទះអូនឯងមួយផង ខ្លួនឆ្លើយថា បងយកទុកមុខផ្ទះសិនទៅ ឈ្មោះ កណ្តុរ បានយកម៉ូតូទុកមុខផ្ទះ និងផ្ញើដាវកែច្នៃចំនួន ពីរ និងកណ្តៀវ មួយផងដែរ។ បន្ទាប់មកពួកគាត់បានចេញទៅបាត់ទៅ ប៉ុន្តែខ្លួនមិនដឹងថាពួកគាត់ទៅណាទេ។ លុះដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០នាទី មានកម្លាំងសមត្ថកិច្ច បានមកហៅខ្លួនទៅប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកថ្មីតែម្តង។

-មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងចម្លើយជនជាប់ចោទ, ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយសាក្សី, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ, សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងតាមការពិនិត្យឯកសារភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងបញ្ជាក់ថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង១០នាទី ទៀបភ្លឺ ស្ថិតនៅចំណុចភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានបក្ខពួកជនជាប់ចោទចំនួន ១០នាក់ មានឈ្មោះ [redacted] សីហតុន, ឈ្មោះ [redacted] សិទ្ធិគុណ, ឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] ម៉េងគួ,ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្ទិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ, ឈ្មោះ [redacted] មីណា,ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហួរ បានរៀបចំសកម្មភាពកាប់យកម៉ូតូគេនៅតាមដងផ្លូវ ដោយមានមធ្យោបាយធ្វើសកម្មភាពម៉ូតូចំនួន ០៥គ្រឿង។ ពេលដែលកំពុងធ្វើសកម្មភាពតាមដងផ្លូវ បក្ខពួកជនជាប់ចោទ ក៏បានប្រទះឃើញជនរងគ្រោះឈ្មោះ [redacted] គឹមលាង ជិះម៉ូតូមួយគ្រឿងម៉ាក HONDA SCOOPY ពណ៌ស ស៊េរីឆ្នាំ២០២១ ពាក់ផ្លាកលេខ កណ្តាល 1AM-6603 កំពុងធ្វើដំណើរតែម្នាក់ឯង បក្ខពួកជនជាប់ចោទ ក៏បានជិះម៉ូតូកៀរម៉ូតូរបស់ជនរងគ្រោះ រួចបានយកកាំបិតប៉ុងតោ កាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] គឹមលាង ចំក្បាលចំនួន០៣កាំបិត និងខ្នងចំនួន ០២កាំបិត រួចបានយកម៉ូតូគេចខ្លួនទៅភ្នំពេញបាត់ ហើយបន្ទាប់មកបក្ខពួកជនជាប់ចោទឈ្មោះ [redacted] ម៉េងគួ ក៏បានទូរស័ព្ទប្រាប់ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សីហតុន, ឈ្មោះ [redacted] សិទ្ធិគុណ និងឈ្មោះ [redacted] លីហួរ ថា ពួកខ្លួនយកម៉ូតូបានមួយគ្រឿងហើយ ឱ្យបក្ខពួករង់ចាំនៅស្ពានច្បារអំពៅចាំទទួលដើម្បីចាត់ចែងបន្ត។ បន្ទាប់មកឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សីហតុន, ឈ្មោះ [redacted] សិទ្ធិគុណ និងឈ្មោះ [redacted] លីហួរ បានរង់ចាំបក្ខពួកខ្លួននៅម្តុំច្បារអំពៅ ហើយក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបានចំនួន ០៣នាក់ មានឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សីហតុន និងឈ្មោះ [redacted] សិទ្ធិគុណ ចំណែកឯឈ្មោះ [redacted] លីហួរ បាត់រត់គេចខ្លួនបាត់។ នៅពេលនោះបក្ខពួកផ្សេងទៀត ក៏បានយកម៉ូតូ០១គ្រឿងដែលកាប់បាននោះ ទៅលក់នៅម្តុំផ្សារឃ្លាំងរំសេវ បានប្រាក់ចំនួន ៩០០(ប្រាំបួនរយ)ដុល្លារអាមេរិក។ ហើយចំពោះអាវុធសម្រាប់ធ្វើសកម្មភាពនោះ គឺឈ្មោះ ស្ទិត និងឈ្មោះ កណ្តុរ យកពីក្រោយផ្ទះរបស់ឈ្មោះ [redacted] សុភារម្យ ដែលបានលាក់ទុកនៅទីនោះ ហើយឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សីហតុន និងឈ្មោះ [redacted] សិទ្ធិគុណ សុទ្ធតែបានដឹងពីផែន



Scanned with CamScanner

ការទាំងអស់របស់បក្ខពួកខ្លួន។ នេះជាអំពើ **លួចមានស្ថានទម្ងន់ទោស** ដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ យ៉ាងពិតប្រាកដ។

-ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សិទ្ធិគុណ, ឈ្មោះ [redacted] សីហាគុន, ឈ្មោះ [redacted] ម៉េងគួ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ [redacted] ម៉េងហាក់ , ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហួរ ជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដែលបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុភារម្យ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សិទ្ធិគុណ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] សីហាគុន ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងគួ ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត ភេទប្រុស អាយុ ១៦ឆ្នាំ, ឈ្មោះ [redacted] ជាតិ ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] មីណា ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្តុរ ភេទប្រុស អាយុ ២០ឆ្នាំ, ឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] លីហួរ ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទៈ **លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ)** ប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- **វត្ថុចាប់យករួមមាន** ម៉ូតូ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1HT-0521 ត្រូវបានចៅក្រមស៊ើបសួរ សម្រេចប្រគល់វត្ថុចាប់យកទៅឱ្យម្ចាស់ដើមវិញហើយ តាម ដីកាសម្រេចលេខ ៧៣៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ រួចហើយ។ ហេតុដូច្នេះ តុលាការមិនលើកយកមកពិចារណានោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមលាង** មិនបានចូលមកសវនាការជំនុំជម្រះ ដើម្បីប្តឹងទាមទារសំណងពីជនជាប់ចោទឡើយ ហេតុដូច្នេះ តុលាការគ្មានមូលដ្ឋានក្នុងការសម្រេចពីសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សិទ្ធិគុណ, ឈ្មោះ [redacted] សីហាគុន, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្វិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា ជាអនីតិជន នៅឡើយ ហេតុនេះ គប្បីតុលាការពិចារណាពីផ្តន្ទាទោសជនជាប់ចោទតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

១.១-ឈ្មោះ [redacted] **សុភារម្យ** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

១.២-ឈ្មោះ [redacted] **សិទ្ធិគុណ** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

១.៣-ឈ្មោះ [redacted] **សីហាគុន** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

១.៤.ឈ្មោះ [redacted] **ម៉េងគួ** ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ។

១.៥.ឈ្មោះ [redacted] **វ៉ាន់ថា ហៅ ស្វិត** ភេទប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

១.៦.ឈ្មោះ [redacted] **ជាតិ** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។



Scanned with CamScanner

១.៧.ឈ្មោះ [redacted] មីណា ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

១.៨.ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ។

១.៩.ឈ្មោះ ស៊ី ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ។

១.១០.ឈ្មោះ [redacted] លីហ្យូរ ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ។

**ពីបទ លួចមានស្ថានទម្ងន់ទោស (កាប់យកម៉ូតូ)** ប្រព្រឹត្តនៅភូមិចិនកោះ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យចាប់-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ម៉េងគួ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្មិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ, ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហ្យូរ យកមកអនុវត្តទោសក្នុងពន្ធនាគារខេត្តកណ្ដាល គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

-សាលក្រមនេះជំនុំជំរះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភារម្យ, ឈ្មោះ [redacted] សិទ្ធិគុណ និងឈ្មោះ [redacted] សីហាតុន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉េងគួ, ឈ្មោះ [redacted] វ៉ាន់ថា ហៅ ស្មិត, ឈ្មោះ [redacted] ជាតិ, ឈ្មោះ [redacted] មីណា, ឈ្មោះ [redacted] ម៉េងហាក់ ហៅ កណ្ដុរ, ឈ្មោះ ស៊ី និងឈ្មោះ [redacted] លីហ្យូរ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃសុក្រ ១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner